- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.–**

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ផ្តល់ជូនមន្ត្រីរាជការ និងមន្ត្រីនគរបាល ចំនួន ១៨ រូប ផ្តល់ជូនមន្ត្រីរាជការ និងមន្ត្រីនគរបាលច្រកទ្វារអន្តរជាតិកំពង់ផែស្វយ័ត កំពង់ផែឧកញ៉ាម៉ុង និងអាកាសយានដ្ឋានអន្តរជាតិ ខេត្តព្រះសីហនុ ដែលបានលះបង់កំលាំងកាយ ចិត្ត និងបរិច្ចាគថវិកាផ្ទាល់ខ្លួន ជួយកសាងសាលារៀន ប្រព័ន្ធលូទឹក និងជួយថវិកាដល់កាកបាទក្រហមកម្ពុជា នៅខេត្តព្រះសីហនុ ដែលមានរាយនាមដូចខាងក្រោម :

១-លោកវរសេនីយ៍ត្រី **ឌឹម សិលា** នាយរងប៉ុស្តិ៍នគរបាលច្រកទ្វារអន្តរជាតិ អត្តលេខ ០៧២៧៣

២-លោកវរសេនីយ៍ត្រី **ស្វាយ រិន** នាយផ្នែកការិយាល័យប្រមូលពត៌មាន អត្តលេខ ០៥៧៧៤

៣-លោកវរសេនីយ៍ត្រី **ស្រ៊ិន សារ៉េត** នាយរងប៉ុស្តិ៍នគរបាលច្រកទ្វារអន្តរជាតិ អត្តលេខ ៣៦១៦

៤-លោកវរសេនីយ៍ត្រី **ថោង ឧត្តី,** នាយរងប៉ុស្តិ៍នគរបាលច្រកទ្វារអន្តរជាតិ អត្តលេខ ០៤៧៤៤

៥-លោកវរសេនីយ៍ត្រី **ស្រី ឈឿន** នាយរងប៉ុស្តិ៍នគរបាលច្រកទ្វារអន្តរជាតិ អត្តលេខ ១៦៣១១

៦-លោកវរសេនីយ៍ត្រី **សៀម សុភា** នាយផ្នែកការិយាល័យជនបរទេសមិនមែនអន្តោប្រវេសន៍ អត្តលេខ ៦១៦៦៦

៧-លោកអនុសេនីយ៍ឯក ស្រ៊ុន ម៉ុង នាយផ្នែកការិយាល័យជនភៀសខ្លួន អត្តលេខ ៣១១៦០

៨-លោកអនុសេនីយ៍ឯក ឃុ គឹមសុន នាយផ្នែកប៉ុស្តិ៍នគរបាលច្រកទ្វារអន្តរជាតិ អត្តលេខ ៣៣១០២

៩-លោកអនុសេនីយ៍ឯក ហ៊ិន គឹមហុង នាយរងប៉ុស្តិ៍នគរបាលច្រកទ្វារអន្តរជាតិ អត្តលេខ ១៦២៨៦

១០-លោកអនុសេនីយ៍ឯក សុខ គួង នាយផ្នែកប៉ុស្តិ៍នគរបាលច្រកទ្វារអន្តរជាតិ អត្តលេខ ៣៤៣២៨

១១-លោកអនុសេនីយ៍ឯក ម៉ឿន សុវណ្ណា នាយរងផ្នែកប៉ុស្តិ៍នគរបាលច្រកទ្វារអន្តរជាតិ អត្តលេខ ១៦៣០៣

១២-លោកអនុសេនីយ៍ឯក ពុធ ឌីណា នាយរងផ្នែកប៉ុស្តិ៍នគរបាលច្រកទ្វារអន្តរជាតិ អត្តលេខ ៥៦១៨៩

១៣-លោកអនុសេនីយ៍ទោ តាំង អ៊ុយម៉េង នាយរងផ្នែកប៉ុស្តិ៍នគរបាលច្រកទ្វារអន្តរជាតិ អត្តលេខ ៥៦១៨៨

១៤-លោកអនុសេនីយ៍ទោ តូច សំអឿន នាយរងផ្នែកប៉ុស្តិ៍នគរបាលច្រកទ្វារអន្តរជាតិ អត្តលេខ ៥៩៥០៩

១៥-លោកអនុសេនីយ៍ទោ ជួប ចាន់ឌី នាយរងផ្នែកប៉ុស្តិ៍នគរបាលច្រកទ្វារអន្តរជាតិ អត្តលេខ ៥៥៥៨០

១៦-លោកអនុសេនីយ៍ទោ ជុំ ចរិន នាយរងផ្នែកប៉ុស្តិ៍នគរបាលច្រកទ្វារអន្តរជាតិ អត្តលេខ ៥៦៣១៩

១៧-លោកអនុសេនីយ៍ទោ សាវ សម្ផស្ស នាយរងផ្នែកប៉ុស្តិ៍នគរបាលច្រកទ្វារអន្តរជាតិ អត្តលេខ ៥៧៤៧៧

១៨-លោកអនុសេនីយ៍ទោ សៅ សុភាព មន្ត្រីការិយាល័យជនបរទេសមិនមែនអន្តោប្រវេសន៍ អត្តលេខ ៥៤៨៤៨

**មាត្រា ២.–**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាលខេត្តព្រះសីហនុ និងសាមីខ្លួន ដែលមានឈ្មោះក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

__កន្លែងទទួល :__

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៨៩៤ អនក្រ.តត

## អនុក្រឹត្យ
## ស្តីពីការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យ លេខ ៨៤ អនក្រ.បក ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យ លេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រងការអនុវត្តន៍ ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

**មាត្រា ១:** តែងតាំងលោក **ចាន់ សុនា** ជាប្រធាននាយកដ្ឋានបឋមសិក្សា នៃក្រសួងអប់រំ យុវជន និងកីឡា ជំនួសលោក **យ៉ោក សុវណ្ណ** ដែលត្រូវបានដាក់ឱ្យចូលនិវត្តន៍ ។

**មាត្រា ២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ... ខែ កញ្ញា ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៩៩៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយសុវត្ថារា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើររបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយសុវត្ថារា** តាមលំដាប់ថ្នាក់ជូនដល់ នាយនគរបាលជាតិ និងមន្ត្រីរាជការ ដែលបានកសាងសមិទ្ធផលនានា ក្នុងស្រុកពាមជរ ខេត្តព្រៃវែង :

**ក. មេដាយសុវត្ថារា ថ្នាក់ធិបឌិន្ទ**

| | | |
|---|---|---|
| ១-លោក | **ឆន សុគន្ធ** | អនុប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត |
| ២-លោក | **ដេង ឧត្តី** | ប្រធានការិ.រដ្ឋបាលបុគ្គលិក និងហិរញ្ញវត្ថុ |
| ៣- លោក | **សុន សារឿន** | ប្រធានការិ.ថវិកា |
| ៤-លោក | **ស្រ៊ាង បុផា** | អនុប្រធានការិ.ថវិកា |
| ៥- លោក | **ឈួន ខេមរិទ្ធិ** | អនុប្រធានការិ.លទ្ធកម្មសាធារណៈ |
| ៦- លោក | **ម៉នី ជីវិត** | នាយករងហិរញ្ញវត្ថុ សាលាខេត្តព្រះសីហនុ |
| ៧- លោកវរៈសេនីយ៍ទោ | **សួន គីមស៊ាន់** | នាយការិយាល័យផ្គត់ផ្គង់ ក្រសួងមហាផ្ទៃ |
| ៨- លោកវរៈសេនីយ៍ត្រី | **ស៊ី ចន្ថា** | នាយផ្នែកនាយកដ្ឋាននគរបាលការពារ |
| ៩- លោកវរៈសេនីយ៍ត្រី | **សោម សុនីន** | នាយរងការិ.នាយកដ្ឋាននគរបាលការពារបេតិកភ័ណ្ឌ |
| ១០- លោកអនុសេនីយ៍ទោ | **ព្រាំ ខាវី** | ប្រធានផ្នែកនាយកដ្ឋាននគរបាលការពារបេតិកភ័ណ្ឌ |
| ១១- លោកអនុសេនីយ៍ទោ | **ទ៉ាយ ហុខ** | អនុប្រធានផ្នែកនាយកដ្ឋាននគរបាលការពារ បេតិកភ័ណ្ឌ |
| ១២-លោកអនុសេនីយ៍ទោ | **វឿល សោភា** | អធិការរងនគរបាលស្រុក |
| ១៣-លោកអនុសេនីយ៍ទោ | **ស៊ុំ កុសល** | អធិការរងនគរបាលស្រុក |

**ខ. មេដាយសុវត្ថារា ថ្នាក់សេនា**

| | | |
|---|---|---|
| ១-លោកវរសេនីយ៍ទោ | **លីម វណ្ណធី** | នាយការិ.នាយកដ្ឋាននគរបាលបច្ចេកទេសព្រំដែន |
| ២-លោកវរសេនីយ៍ត្រី | **សួន សារ៉ាត** | អត្តលេខ០៣៨៨៧ អធិការនគរបាលស្រុកពាមជរ |
| ៣-លោកអនុសេនីយ៍ទោ | **ម៉ៅ លីណា** | នាយរងផ្នែក នាយកដ្ឋាននគរបាលព្រំដែនទឹកក្រសួងមហាផ្ទៃ |
| ៤-លោកអនុសេនីយ៍ត្រី | **ចឹម ណារិទ្ធ** | នាយរងផ្នែក នាយកដ្ឋាននគរបាលព្រំដែនទឹកក្រសួងមហាផ្ទៃ |
| ៥-លោកអនុសេនីយ៍ត្រី | **មៀច ចន្ទូ** | មន្ត្រីនាយកដ្ឋាននគរបាលព្រំដែនទឹកក្រសួងមហាផ្ទៃ |
| ៦-លោក | **សារ៉ែត ចំនួនចាវ៉ូ** | អនុប្រធមន្ទីរផែនការខេត្ត |
| ៧-លោក | **គាំង ណាង** | អនុប្រធានស្នងការគយ និងរដ្ឋាករកោះសំពៅ |
| ៨-លោក | **ម៉ៅ វណ្ណឈឿន** | នាយផ្នែកពតិមានក្រៅប្រទេស |

**គ. មេដាយសុវត្ថារា ថ្នាក់អស្សឫទ្ធិ**

| | | |
|---|---|---|
| ១-លោក | **ថោង សុភាព** | ប្រធានគណនេយ្យពេទ្យបង្អែកស្រុកព្រះស្តេច |
| ២-អនុសេនីយ៍ឯក | **អ៊ុន សុខានណារិទ្ធ** | អធិការរងនគរបាលស្រុកពាមរក៍ |
| ៣-អនុសេនីយ៍ឯក | **យឿង សុវណ្ណ** | នាយផ្នែកនៃស្នងការដ្ឋាននគរបាលខេត្តព្រៃវែង |
| ៤-អនុសេនីយ៍ទោ | **ស៊ិន រីណារ** | នាយផ្នែកនៃស្នងការដ្ឋាននគរបាលខេត្តព្រៃវែង |
| ៥-អនុសេនីយ៍ទោ | **ស៊ឹម ម៉ុង** | នាយផ្នែកនៃស្នងការដ្ឋាននគរបាលខេត្តព្រៃវែង |
| ៦-អនុសេនីយ៍ត្រី | **ឡោ សេងគេង** | មន្ត្រី នាយកដ្ឋាននគរបាលអន្តរជាតិ |
| ៧-អនុសេនីយ៍ត្រី | **នាង ម៉ៅ** | មន្ត្រី នាយកដ្ឋាននគរបាលអន្តរជាតិ |
| ៨-អនុសេនីយ៍ត្រី | **សៅ ចាន់ថា** | នាយផ្នែកនៃអធិការដ្ឋាននគរបាលស្រុក |
| ៩-អនុសេនីយ៍ទោ | **នេព ផល្លា** | ប្រធានប៉ុស្តិ៍នគរបាលឃុំព្រែកក្របៅ |
| ១០-អនុសេនីយ៍ទោ | **ឈឹម សារឿន** | ប្រធានប៉ុស្តិ៍នគរបាលឃុំស្វាយភ្លោះ |
| ១១-អនុសេនីយ៍ទោ | **មាន ចន្ថា** | ប្រធានប៉ុស្តិ៍នគរបាលឃុំព្រែកសំបួរ |
| ១២-អនុសេនីយ៍ទោ | **ឡុង ណារាត** | ប្រធានប៉ុស្តិ៍នគរបាលឃុំកោះរកា |
| ១៣-អនុសេនីយ៍ទោ | **កុង ណារុន** | ប្រធានប៉ុស្តិ៍នគរបាលឃុំកោះសំពៅ |
| ១៤-អនុសេនីយ៍ទោ | **សេង វុត្ថា** | ប្រធានប៉ុស្តិ៍នគរបាលឃុំកំពង់ប្រាសាទ |
| ១៥-អនុសេនីយ៍ទោ | **ម៉ែន យល់** | ប្រធានប៉ុស្តិ៍នគរបាលឃុំអង្គរអង្គ |
| ១៦-អនុសេនីយ៍ទោ | **សំ គាដ** | ប្រធានប៉ុស្តិ៍នគរបាលឃុំក្រាំងតាយ៉ង |
| ១៧-អនុសេនីយ៍ត្រី | **ស៊ិន ស៊ីណារាត** | ប្រធានប៉ុស្តិ៍នគរបាលឃុំកោះចេក |
| ១៨-អនុសេនីយ៍ត្រី | **កែន សុខុន** | ប្រធានប៉ុស្តិ៍នគរបាលឃុំឫស្សីស្រុក |

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តព្រៃវែង ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផល។

រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១០

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៩៧៥ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ
## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើររបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ជូនដល់ នាយគរបាលជាតិ មន្ត្រីរាជការ និងសប្បុរសជន ដែលបានកសាងសមិទ្ធិផលនានា ក្នុងស្រុកពាមជរ ខេត្តព្រៃវែង :

**ក. មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ធិបឌិន្ទ**

១-លោកវរសេនីយ៍ទោ **ទូ ហាក់** ប្រធានអង្គភាពបង្ក្រាបបទល្មើសលើផ្ទៃសមុទ្រ

២-លោកវរៈសេនីយ៍ទោ **ម៉ាន ចន្ថា** នាយការិ.នាយកដ្ឋាននគរបាលអន្តរជាតិ

៣-លោកអនុសេនីយ៍ឯក **ឆាយ យោន** នាយផ្នែក នាយកដ្ឋាននគរបាលព្រំដែនទឹកក្រសួងមហាផ្ទៃ

៤-លោកអនុសេនីយ៍ត្រី **សួន សុជាតិ** មន្ត្រីនាយកដ្ឋាននគរបាលព្រំដែនទឹកក្រសួងមហាផ្ទៃ

៥-លោក **ឡាយ សុគន្ធ** សប្បុរសជននៅរាជធានីភ្នំពេញ

៦-លោក **ចំន្ទ ទាសនា** សប្បុរសជននៅរាជធានីភ្នំពេញ

**ខ. មេដាយមុនីសារាភ័ណ្ឌ ថ្នាក់សេនា**

១-លោកវរៈសេនីយ៍ត្រី **សួន រីម** នាយការិ.ស្នងការដ្ឋាននគរបាលខេត្តកំពត

២-លោកអនុសេនីយ៍ឯក **ខ៊ែត សេរីវុធ** នាយផ្នែក នាយកដ្ឋាននគរបាលព្រំដែនទឹកក្រសួងមហាផ្ទៃ

៣-លោកអនុសេនីយ៍ឯក **ស្រី រ៉ា** នាយផ្នែក នាយកដ្ឋាននគរបាលព្រំដែនទឹកក្រសួងមហាផ្ទៃ

៤-លោកអនុសេនីយ៍ត្រី **ផុំង កង** នាយផ្នែក នាយកដ្ឋាននគរបាលព្រំដែនទឹកក្រសួងមហាផ្ទៃ

៥-លោកអនុសេនីយ៍ត្រី **ហុង ជុនយាន** មន្ត្រី នាយកដ្ឋាននគរបាលព្រំដែនទឹកក្រសួងមហាផ្ទៃ

**គ. មេដាយមុនីសារាភណ្ឌ ថ្នាក់អស្សឫទ្ធិ**

១- អនុសេនីយ៍ទោ **ម៉ៅ សុឌ្ឍាគុណ** អនុប្រធានផ្នែកស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តព្រៃវែង ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**គណៈកម្មការមូលបត្រកម្ពុជា**

លេខ:.......០០៨/១០....គ.ម.ក/ប្រ.ក

លិខិតចូល

ថ្ងៃទី២៧ ខែ[illegible] ឆ្នាំ២០១០

**ប្រកាស**

**ស្តីពី**

**ការទទួលស្គាល់ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ**

* * * * *

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**និងជាប្រធានគណៈកម្មការមូលបត្រកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០១ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមូលបត្ររដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ/បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ/បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- យោងតាមការអនុម័តនៃសម័យប្រជុំពេញអង្គរបស់គណៈកម្មការមូលបត្រកម្ពុជា នាថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១០

អាសយដ្ឋានបណ្តោះអាសន្ន អគារ ៩៩ ផ្លូវ ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ-កម្ពុជា ទូរស័ព្ទ : ៨៥៥-២៣-៨៨៥-៦១១ ទូរសារ : ៨៥៥-២៣-៨៨៥-៦២២
Temporary Address: # 99, Street 598, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh, Cambodia. www.secc.gov.kh
Phone : 855-23-885-611 Fax : 855-23-885-622
E-mail : info@secc.gov.kh

# ស ម្រេ ច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-គោលបំណង**

ប្រកាសនេះមានគោលបំណងកំណត់នូវលក្ខខណ្ឌតម្រូវ នីតិវិធីដើម្បីទទួលស្គាល់បុគ្គលធ្វើជាភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ និងកំណត់អំពីកាតព្វកិច្ចរបស់ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ដោយអនុលោមតាមច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន និងអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន។

**ប្រការ ២.-និយមន័យ**

និយមន័យនៃពាក្យបច្ចេកទេសដែលប្រើប្រាស់នៅក្នុងប្រកាសនេះ ត្រូវបានកំណត់នៅក្នុងប្រការនេះ និងមាននៅក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន និងអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន។

-ច្បាប់ (Law) សំដៅដល់ច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន។

-អនុក្រឹត្យ (Anukret) សំដៅដល់អនុក្រឹត្យ លេខ ៥៤ អនក្រ/បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។

-ប្រព័ន្ធជាត់ទាត់និងទូទាត់ (Clearance and Settlement Facility) សំដៅដល់ប្រព័ន្ធដែលផ្តល់លទ្ធភាពដល់ភាគីធ្វើប្រតិបត្តិការជួញដូរមូលបត្រ បំពេញកាតព្វកិច្ចរបស់ខ្លួនទៅវិញទៅមកបាន ដោយធ្វើការផ្ទៀងផ្ទាត់ប្រតិបត្តិការឱ្យបានច្បាស់លាស់ និងធានាឱ្យមានការទូទាត់ថ្លៃទិញជូនអ្នកលក់ ដែលជាថ្នូរនឹងការផ្ទេរកម្មសិទ្ធិមូលបត្រទៅឱ្យអ្នកទិញ។ ប្រព័ន្ធជាត់ទាត់និងទូទាត់ រួមមាន៖

ក-ប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ (Securities Clearance and Settlement Facility) សំដៅដល់ប្រព័ន្ធជាត់ទាត់និងទូទាត់ ដើម្បីធ្វើការផ្លាស់ប្តូរកម្មសិទ្ធិលើមូលបត្ររវាងភាគីធ្វើប្រតិបត្តិការជួញដូរមូលបត្រ។

ខ-ប្រព័ន្ធជាត់ទាត់និងទូទាត់សាច់ប្រាក់ (Cash Clearance and Settlement Facility) សំដៅដល់ប្រព័ន្ធជាត់ទាត់និងទូទាត់ ដើម្បីធ្វើការផ្ទេរ ឬបង្វែរសាច់ប្រាក់ រវាងភាគីធ្វើប្រតិបត្តិការជួញដូរមូលបត្រ។

-បុគ្គលដាក់ពាក្យស្នើសុំ (Applicant) សំដៅដល់បុគ្គលដាក់ពាក្យស្នើសុំធ្វើជាភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ។

-បុគ្គលិកជាន់ខ្ពស់ (Senior Staff) សំដៅដល់បុគ្គលិកដែលមានឋានៈចាប់ពីអគ្គនាយករហូតដល់នាយកឬប្រធានផ្នែក និងសវនករផ្ទៃក្នុង។

## ជំពូកទី ២
## លក្ខខណ្ឌនៃការទទួលស្គាល់ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ

### ប្រការ ៣.- បុគ្គលដែលអាចធ្វើជាភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ

បុគ្គលដែលមានបំណងធ្វើជាភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ត្រូវដាក់ពាក្យស្នើសុំ និងត្រូវបានទទួលស្គាល់ពីអគ្គនាយកនៃ **គ.ម.ក.** ដោយអនុលោមតាមច្បាប់ អនុក្រឹត្យ និងប្រកាសនេះ។

### ប្រការ ៤.- ការទទួលស្គាល់ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ

បុគ្គលដាក់ពាក្យស្នើសុំ ត្រូវជាធនាគារពាណិជ្ជដែលទទួលបានអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា ដោយអនុលោមតាមច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ និងបទប្បញ្ញត្តិពាក់ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា និងត្រូវទទួលបានជាមុននូវលិខិត "មិនជំទាស់" ពីធនាគារជាតិនៃកម្ពុជា។

### ប្រការ ៥.- លក្ខខណ្ឌតម្រូវ

បុគ្គលដាក់ពាក្យស្នើសុំធ្វើជាភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រត្រូវ ÷

១-មានក្របខណ្ឌ និងនីតិវិធីអភិបាលកិច្ចសាជីវកម្មរឹងមាំ។

២-មានភាពរឹងមាំខាងផ្នែកហិរញ្ញវត្ថុ និងសមត្ថភាពប្រតិបត្តិការខ្ពស់។

៣-មានធនធានមនុស្សប្រកបដោយចំណេះដឹង សមត្ថភាព និងបទពិសោធន៍ខ្ពស់ សមស្រប នៅក្នុងវិស័យមូលបត្រ ធនាគារ ហិរញ្ញវត្ថុ និងពាណិជ្ជកម្ម សម្រាប់ប្រតិបត្តិការ

ទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ និងត្រូវមានអត្តចរិតល្អដូចមានចែងក្នុងមាត្រាទ ៤២ នៃអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន។

៤-មានប្រព័ន្ធបច្ចេកវិទ្យា និងយន្តការនានា ដែលធានាឱ្យប្រតិបត្តិការទូទាត់ មានល្បឿនរហ័ស សុវត្ថិភាព និងស្ថេរភាពខ្ពស់។

៥-មានបច្ចេកវិទ្យាដែលធានាការភ្ជាប់ទំនាក់ទំនង ប្រកបដោយប្រសិទ្ធភាព ជាមួយប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ ប្រព័ន្ធទូទាត់សាច់ប្រាក់ និងក្រុមហ៊ុនមូលបត្រដែលជាអតិថិជនរបស់ខ្លួនជាដើម។

៦-មានប្រព័ន្ធទ្រទ្រង់ (Back-up System) និងផែនការយថាភាព (Contingency Plan) សមស្រប ដើម្បីកាត់បន្ថយនូវហានិភ័យដែលកើតចេញពីអាជីវកម្ម ឬប្រតិបត្តិការណាមួយ (Operational Risks) ជាយថាហេតុ។

៧-មាននីតិវិធីច្បាស់លាស់ ក្នុងការផ្តល់សេវានានាដល់អតិថិជនដែលធ្វើប្រតិបត្តិការជួញដូរមូលបត្រ ក្នុងការទូទាត់សាច់ប្រាក់។

៨-គោរពតាមលក្ខខណ្ឌតម្រូវពាក់ព័ន្ធនានារបស់ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ។

## ប្រការ ៦.- ឯកសារភ្ជាប់ជាមួយពាក្យស្នើសុំ

បុគ្គលដាក់ពាក្យស្នើសុំត្រូវបំពេញបែបបទនៃពាក្យស្នើសុំទៅតាមទម្រង់ដែលបានកំណត់ដោយ **គ.ម.ក.** ដោយភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម ÷

១-អាជ្ញាប័ណ្ណធនាគារពាណិជ្ជថតចម្លងមានបញ្ជាក់ត្រឹមត្រូវ។

២-ប័ណ្ណប៉ាតង់ថតចម្លងមានបញ្ជាក់ត្រឹមត្រូវ។

៣-លក្ខន្តិកៈក្រុមហ៊ុនថតចម្លងមានបញ្ជាក់ត្រឹមត្រូវ។

៤-លិខិតបញ្ជាក់ពីដើមទុន និងលិខិតបញ្ជាក់ពីប្រាក់តម្កល់ ប្រាក់បម្រុងកាតព្វកិច្ចចេញដោយធនាគារជាតិនៃកម្ពុជា។

៥-ព័ត៌មានពាក់ព័ន្ធនឹងក្របខណ្ឌ និងនីតិវិធីអភិបាលកិច្ចសាជីវកម្ម។

៦-បញ្ជីរាយនាមភាគហ៊ុនិក ដោយបញ្ជាក់ពីចំនួនហ៊ុន និងភ្ជាប់មកជាមួយនូវអត្តសញ្ញាណបណ្ណឬលិខិតឆ្លងដែនថតចម្លង ដោយមានចុះហត្ថលេខាឬស្នាមម្រាមដៃរបស់ភាគហ៊ុនិកនីមួយៗ។

៧-បញ្ជីរាយនាមអភិបាលក្រុមហ៊ុន ដោយបញ្ជាក់ពីតួនាទីនិងបទពិសោធន៍ការងារ និងភ្ជាប់មកជាមួយនូវអត្តសញ្ញាណបណ្ណ ឬលិខិតឆ្លងដែនថតចម្លង ដោយមានចុះហត្ថលេខា ឬ ស្នាមម្រាមដៃរបស់អភិបាលនីមួយៗ ព្រមទាំងលិខិតថ្កោលទោស។

៨-អង្គការលេខស្តីពីរចនាសម្ព័ន្ធរបស់ក្រុមហ៊ុន និងបញ្ជីរាយនាមបុគ្គលិកជាន់ខ្ពស់ពាក់ព័ន្ធរបស់ក្រុមហ៊ុនដោយបញ្ជាក់ពីតួនាទី និងបទពិសោធន៍ការងារ និងភ្ជាប់មកជាមួយនូវអត្តសញ្ញាណបណ្ណ ឬលិខិតឆ្លងដែនថតចម្លងដោយមានចុះហត្ថលេខាឬស្នាមម្រាមដៃរបស់បុគ្គលិកជាន់ខ្ពស់នីមួយៗ ព្រមទាំងលិខិតថ្កោលទោស។

៩-នីតិវិធីប្រតិបត្តិការពាក់ព័ន្ធនឹងប្រតិបត្តិការដែលជាសកម្មភាពធនាគារ និងប្រតិបត្តិការទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ។

១០-ផែនការអាជីវកម្មសម្រាប់រយៈពេលយ៉ាងតិច ០៣ (បី) ឆ្នាំ ដោយគិតចាប់ពីកាលបរិច្ឆេទនៃការដាក់ពាក្យស្នើសុំ។

១១-របាយការណ៍ហិរញ្ញវត្ថុ ឬ របាយការណ៍ហិរញ្ញវត្ថុរួមដែលធ្វើសវនកម្មរួច សម្រាប់រយៈពេល ០៣ (បី) ឆ្នាំចុងក្រោយ។

១២-ផែនការគ្រប់គ្រងហានិភ័យ និងផែនការយថាភាព (Contingency Plan) ដែលមានលក្ខណៈបច្ចុប្បន្នភាព ជាពិសេសសម្រាប់ប្រតិបត្តិការទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ។

អគ្គនាយកនៃ **គ.ម.ក.** អាចតម្រូវឱ្យបុគ្គលដាក់ពាក្យស្នើសុំ ផ្តល់ឯកសារបន្ថែម ឬបំភ្លឺនូវចំណុច ឬព័ត៌មានផ្សេងៗទៀត តាមការចាំបាច់។

## ប្រការ ៧.- ការបដិសេធលើពាក្យស្នើសុំ

អគ្គនាយកនៃ **គ.ម.ក.** អាចបដិសេធលើពាក្យស្នើសុំធ្វើជាភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ដោយផ្អែកលើមូលហេតុដូចខាងក្រោម ÷

១-បុគ្គលដាក់ពាក្យស្នើសុំមិនបានបំពេញនូវលក្ខខណ្ឌណាមួយ ដែលមានចែងក្នុងប្រកាសនេះ ឬសេចក្តីណែនាំផ្សេងទៀតដែលធ្វើនៅក្រោមប្រកាសនេះ ឬបទប្បញ្ញត្តិជាធរមានដែលពាក់ព័ន្ធផ្សេងទៀត។

២-ព័ត៌មាន ឬឯកសារដែលបុគ្គលដាក់ពាក្យស្នើសុំបានដាក់ទៅ **គ.ម.ក.**មានលក្ខណៈក្លែងបន្លំ ឬដែលនាំឱ្យយល់ខុស។

៣-បុគ្គលដាក់ពាក្យស្នើសុំស្ថិតក្នុងស្ថានភាពឈានទៅរកការបញ្ឈប់ ឬរំលាយអាជីវកម្ម។

៤-សេចក្តីសម្រេចរបស់តុលាការ ដែលតម្រូវឱ្យបុគ្គលដាក់ពាក្យស្នើសុំទូទាត់សងបំណុល មិនត្រូវបានអនុវត្តទាំងស្រុង ឬមួយផ្នែកដោយបុគ្គលដាក់ពាក្យស្នើសុំនោះ។

៥-បុគ្គលដាក់ពាក្យស្នើសុំ ឬអភិបាល ឬបុគ្គលិកជាន់ខ្ពស់ពាក់ព័ន្ធរបស់បុគ្គលដាក់ពាក្យស្នើសុំ ÷

ក-បានធ្វើអាជីវកម្មដែលមានលក្ខណៈបោកបញ្ឆោត ឬកេងប្រវ័ញ្ច ឬមិនត្រឹម-ត្រូវ ដោយប្រការណាមួយ។

ខ-បានប្រព្រឹត្តល្មើសនឹងច្បាប់ និងបទប្បញ្ញត្តិ ដែលការពារសាធារណជនឱ្យចៀសផុតពីការខាតបង់ផ្នែកហិរញ្ញវត្ថុ ដោយសារតែភាពមិនស្មោះត្រង់ ឬអសមត្ថភាព ឬការប្រព្រឹត្តមិនត្រឹមត្រូវរបស់បុគ្គលនោះ ក្នុងការផ្តល់សេវាហិរញ្ញវត្ថុ ឬក្នុងការគ្រប់គ្រងក្រុមហ៊ុន។

គ-បានធ្វើ ឬជាប់ពាក់ព័ន្ធនឹងអាជីវកម្មណាមួយផ្សេងទៀត ដែលធ្វើឱ្យមានការសង្ស័យចំពោះសមត្ថភាព និងសុក្រឹតភាពនៃសេចក្តីសម្រេចរបស់ខ្លួន។

ឃ-ស្តែងចេញនូវភាពមិនអាចធ្វើសកម្មភាព ដើម្បីផលប្រយោជន៍អតិថិជនរបស់ខ្លួន ដោយសារតែកេរ្តិ៍ឈ្មោះ បុគ្គលិកលក្ខណៈ សេចក្តីសុចរិត និងភាពដែលអាចទុកចិត្តបានផ្នែកហិរញ្ញវត្ថុរបស់បុគ្គលទាំងនោះ។

ង-ស្តែងចេញនូវភាពមិនអាចធ្វើអាជីវកម្មបាន ក្រោមលក្ខខណ្ឌនៃការទទួល-ស្គាល់ ប្រកបដោយប្រសិទ្ធភាព ភាពស្មោះត្រង់ និងយុត្តិធម៌។

៦-បុគ្គលដាក់ពាក្យស្នើសុំ ឬភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់របស់បុគ្គលដាក់ពាក្យស្នើសុំ ធ្លាប់ត្រូវបានប្រកាសក្ស័យធននៅក្នុង ឬនៅក្រៅព្រះរាជាណាចក្រកម្ពុជា ក្នុងរយៈពេល ០៥(ប្រាំ) ឆ្នាំចុងក្រោយ គិតមកត្រឹមកាលបរិច្ឆេទដាក់ពាក្យស្នើសុំ។

៧-នៅពេលកើតមានហេតុការណ៍ណាមួយដែលអាច ÷

ក-នាំឱ្យបុគ្គលដាក់ពាក្យស្នើសុំ ឬអភិបាល ឬបុគ្គលិកជាន់ខ្ពស់ពាក់ព័ន្ធ ឬភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់របស់បុគ្គលដាក់ពាក្យស្នើសុំ មិនអាចធ្វើអាជីវកម្មបានត្រឹមត្រូវ។

ខ-ឆ្លុះបញ្ចាំងពីភាពមិនអាចជឿជាក់បានលើវិធីធ្វើអាជីវកម្មរបស់បុគ្គលដាក់ពាក្យស្នើសុំ។

៨-បុគ្គលដាក់ពាក្យស្នើសុំមាន ឬអាចនឹងមានការពាក់ព័ន្ធនឹងការសំអាតប្រាក់ និង

ហិរញ្ញប្បទានភេរវកម្ម ឬការទទួលស្គាល់បុគ្គលដាក់ពាក្យស្នើសុំ អាចនឹងនាំឱ្យប៉ះពាល់ផលប្រយោជន៍សាធារណៈ។

អគ្គនាយកនៃ **គ.ម.ក.** មិនត្រូវបដិសេធលើពាក្យស្នើសុំធ្វើជាភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ដោយមិនបានផ្តល់មូលហេតុជាលាយលក្ខណ៍អក្សរជាមុន និងមិនបានផ្តល់ឱកាសឱ្យបុគ្គលដាក់ពាក្យស្នើសុំធ្វើការពន្យល់។

## ជំពូកទី ៣
## ការសម្រេចផ្តល់ការទទួលស្គាល់

### ប្រការ ៨.- រយៈពេលនៃការសម្រេចផ្តល់ការទទួលស្គាល់

បន្ទាប់ពី **គ.ម.ក.** ទទួលបានឯកសារ និងព័ត៌មានពេញលេញពីបុគ្គលដាក់ពាក្យស្នើសុំ អគ្គនាយកនៃ **គ.ម.ក.** ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីការទទួលស្គាល់ឬការបដិសេធដល់បុគ្គលដាក់ពាក្យស្នើសុំ ក្នុងរយៈពេលយ៉ាងយូរ ០៣ (បី) ខែ។ ករណីអគ្គនាយកនៃ **គ.ម.ក.** ស្នើសុំឱ្យបុគ្គលដាក់ពាក្យស្នើសុំកែប្រែ ឬផ្តល់ព័ត៌មានបន្ថែមនោះ លក្ខខណ្ឌពេលវេលាក្នុងការពិនិត្យនិងសម្រេចត្រូវគិតសាឡើងវិញ ចាប់តាំងពីកាលបរិច្ឆេទដែលព័ត៌មានទាំងនោះ ត្រូវបានផ្តល់ជូនដល់ **គ.ម.ក.**។

### ប្រការ ៩.- សុពលភាពនៃការទទួលស្គាល់

សុពលភាពនៃការទទួលស្គាល់ មានរយៈពេលមិនកំណត់។

### ប្រការ ១០.- កម្រៃនៃការទទួលស្គាល់ប្រចាំឆ្នាំ និងកម្រៃផ្សេងទៀត

បុគ្គលដាក់ពាក្យស្នើសុំ ត្រូវបង់ថ្លៃពាក្យស្នើសុំនិងសោហ៊ុយសិក្សាសំណុំលិខិតចំនួន ២.០០០.០០០ (ពីរលាន) រៀល។ ថ្លៃពាក្យស្នើសុំនិងសោហ៊ុយសិក្សាសំណុំលិខិតនេះ មិនត្រូវបានប្រគល់ជូនបុគ្គលដាក់ពាក្យស្នើសុំវិញឡើយ ទោះបីជាមានការបដិសេធលើការទទួលស្គាល់ក៏ដោយ។

បុគ្គលដែលទទួលបានការទទួលស្គាល់ ធ្វើជាភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ត្រូវបង់ថ្លៃការទទួលស្គាល់ប្រចាំឆ្នាំចំនួន ៤០.០០០.០០០ (សែសិបលាន) រៀល ដោយគិតចាប់ពីកាលបរិច្ឆេទនៃការទទួលស្គាល់។ សម្រាប់ឆ្នាំបន្តបន្ទាប់ ភ្នាក់ងារទូទាត់សាច់

ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ត្រូវបង់ថ្លៃការទទួលស្គាល់ប្រចាំឆ្នាំយ៉ាងយូរ ៣០ (សាមសិប) ថ្ងៃ មុនថ្ងៃខែ ដែលទទួលបានការទទួលស្គាល់។

## ជំពូកទី ៤
## ភារកិច្ចរបស់ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ

### ប្រការ ១១.- ការចាប់ផ្តើមធ្វើអាជីវកម្ម

បន្ទាប់ពីទទួលបានការទទួលស្គាល់ ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ត្រូវចាប់ផ្តើមប្រតិបត្តិការទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្ររបស់ខ្លួន ក្នុងរយៈពេលយ៉ាងយូរ ០៣(បី)ខែ ដោយគិតចាប់ពីកាលបរិច្ឆេទនៃការទទួលស្គាល់ ឬក្នុងរយៈពេលសមស្រប ដែលអនុញ្ញាតដោយអគ្គនាយកនៃ **គ.ម.ក.**។

### ប្រការ ១២.- ភារកិច្ចទូទៅរបស់ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ

ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រត្រូវ ÷

១-ធ្វើការគ្រប់គ្រងគណនីទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្ររបស់អតិថិជនខ្លួន និងធ្វើការផ្ទេរ ឬបង្វែរសាច់ប្រាក់ រវាងភាគីធ្វើប្រតិបត្តិការជួញដូរមូលបត្រ នៅក្នុងទីផ្សារមូលបត្រ ប្រកបដោយភាពត្រឹមត្រូវ និងតាមកាលកំណត់។

២-ធ្វើប្រតិបត្តិការទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ប្រកបដោយសុវត្ថិភាព និងប្រសិទ្ធភាព។

៣-បំពេញប្រតិបត្តិការទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ឱ្យដាច់ដោយឡែកពីមុខងារប្រតិបត្តិការធនាគារ (Banking Operations)។

៤-ត្រួតពិនិត្យ និងគ្រប់គ្រងដោយប្រុងប្រយ័ត្នខ្ពស់នូវរាល់ហានិភ័យ ដែលកើតឡើងពីអាជីវកម្ម ឬប្រតិបត្តិការណាមួយ។

៥-គោរពយ៉ាងខ្ជាប់ខ្ជួនទៅតាមលក្ខខណ្ឌតម្រូវស្តីអំពីធនធានមនុស្ស ធនធានហិរញ្ញវត្ថុ និងបច្ចេកវិទ្យា សម្រាប់ធានាប្រតិបត្តិការទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ឱ្យដំណើរការប្រកបដោយសុវត្ថិភាព និងប្រសិទ្ធភាព។

៦-គោរពតាមវិធាន និងនីតិវិធីពាក់ព័ន្ធនឹងប្រតិបត្តិការប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ និងវិធានពាក់ព័ន្ធផ្សេងទៀត។

៧-ផ្តល់ភាពងាយស្រួលដល់ការប្រើប្រាស់សេវារបស់ខ្លួន ដើម្បីធានាឱ្យ បាននូវសុវត្ថិភាព និងប្រសិទ្ធភាពនៃប្រតិបត្តិការ។

៨-បំពេញកាតព្វកិច្ចផ្តល់របាយការណ៍និងព័ត៌មាននានា និងកាតព្វកិច្ចដទៃទៀត ឱ្យបានត្រឹមត្រូវ ដូចមានចែងនៅក្នុងច្បាប់ អនុក្រឹត្យ ប្រកាសនេះ និងបទប្បញ្ញត្តិពាក់ព័ន្ធនានា។

## ប្រការ ១៣.- ការគ្រប់គ្រងគណនី

ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ត្រូវធានាថាក្រុមហ៊ុនមូលបត្រដែលជាអតិថិជនរបស់ខ្លួន ដាក់មូលនិធិរបស់អតិថិជនរបស់ពួកគេនៅក្នុងគណនីដាច់ដោយឡែកពីគណនីផ្ទាល់ខ្លួន សម្រាប់ការទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ។

## ប្រការ ១៤.- ការកំណត់កម្រៃសេវាទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ

ការកំណត់កម្រៃសេវានានារបស់ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ត្រូវទទួលបានការអនុញ្ញាតជាមុនពី **គ.ម.ក.** ដោយអនុលោមតាមច្បាប់ អនុក្រឹត្យ ប្រកាសនេះ និងបញ្ញត្តិនានាដែលពាក់ព័ន្ធ។

## ប្រការ ១៥.- ការសុំការអនុញ្ញាត

ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ត្រូវស្នើសុំការអនុញ្ញាតពីអគ្គនាយកនៃ **គ.ម.ក.** ក្នុងករណី ÷

១-បន្ថែម ឬបន្ថយប្រភេទសេវា ដែលអាចធ្វើអោយប៉ះពាល់ដល់ប្រព័ន្ធទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ។

២-កែប្រែកម្រៃសេវាទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ។

៣-កែទម្រង់ប្រព័ន្ធបច្ចេកវិទ្យា និងយន្តការនានា ដែលអាចប៉ះពាល់ដល់ប្រសិទ្ធភាព និងសុវត្ថិភាពប្រតិបត្តិការនៃការទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ។

៤-ផ្អាកជាបណ្តោះអាសន្ន ឬបញ្ឈប់ផ្តល់សេវាទូទាត់សាច់ប្រាក់ដល់អតិថិជនណាមួយរបស់ខ្លួន។

៥-ការវិនិយោគលើធុរកិច្ចផ្សេងទៀតដែលអាចឱ្យប៉ះពាល់ប្រព័ន្ធទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ។

## ប្រការ ១៦.– ការជូនដំណឹង

ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ត្រូវជូនដំណឹង និងរាយការណ៍ជាបន្ទាន់ជូន **គ.ម.ក.** ក្នុងករណីដូចខាងក្រោម ÷

១-មានការរអាក់រអួលខាងផ្នែកបច្ចេកវិទ្យា ដែលធ្វើឱ្យប៉ះពាល់ដល់ប្រតិបត្តិការទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ។

២-មានការសង្ស័យលើអតិថិជនណាមួយ ដែលអាចមានការពាក់ព័ន្ធនឹងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ព្រមទាំងអំពើល្មើសផ្សេងទៀត។

៣-មានអតិថិជនដែលគ្មានលទ្ធភាពធ្វើការទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ។

៤-ករណីផ្សេងទៀតដែលពាក់ព័ន្ធនឹងប្រតិបត្តិការទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ដែលអគ្គនាយកនៃ **គ.ម.ក.** យល់ឃើញថាចាំបាច់។

## ប្រការ ១៧.– ការផ្តល់របាយការណ៍ប្រចាំខែ និងប្រចាំត្រីមាស

ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ត្រូវផ្តល់របាយការណ៍ប្រចាំខែ ក្នុងរយៈពេល ០៥(ប្រាំ)ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីចុងខែនីមួយៗ និងរបាយការណ៍ប្រចាំត្រីមាស ក្នុងរយៈពេល ១០(ដប់)ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីចុងត្រីមាសនីមួយៗជូនទៅ **គ.ម.ក.** ដោយបញ្ជាក់អំពីព័ត៌មានដូចខាងក្រោម ÷

១-ចំនួនប្រតិបត្តិការទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ។

២-ចំនួនប្រតិបត្តិការទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រមិនបានសម្រេច និងការទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រមិនទាន់បានសម្រេច ដោយធ្វើការរៀបរាប់និងពន្យល់ឱ្យបានច្បាស់លាស់ ព្រមទាំងបញ្ជាក់ឈ្មោះក្រុមហ៊ុនមូលបត្រ និងវិនិយោគិនមូលបត្រ។

៣-ស្ថានភាពសាច់ប្រាក់នៅក្នុងគណនីរបស់អតិថិជន ដែលធ្វើប្រតិបត្តិការជួញដូរមូលបត្រ។

៤-ព័ត៌មានផ្សេងទៀត ពាក់ព័ន្ធនឹងប្រតិបត្តិការទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ដែលស្នើសុំដោយអគ្គនាយកនៃ **គ.ម.ក.**។

## ប្រការ ១៨.– ការផ្តល់របាយការណ៍ប្រចាំឆ្នាំ

ក្នុងរយៈពេល ០៣ (បី) ខែ បន្ទាប់ពីឆ្នាំសារពើពន្ធ ឬបន្ទាប់ពីពេលវេលាណាមួយ ដែលអនុញ្ញាតដោយអគ្គនាយកនៃ **គ.ម.ក.** ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ

ត្រូវផ្តល់ជូន គ.ម.ក. នូវរបាយការណ៍អំពីសកម្មភាពទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្ររបស់ខ្លួន នៃឆ្នាំសារពើពន្ធកន្លងទៅ រួមទាំងរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួច និងរបាយការណ៍លម្អិតដូចខាងក្រោម ÷

១-ការកែប្រែនីតិវិធីប្រតិបត្តិការ ក្នុងការផ្តល់សេវានានាក្នុងការទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ។

២-ការផ្លាស់ប្តូរសមាជិកភាពនៃក្រុមប្រឹក្សាភិបាល។

៣-ការផ្លាស់ប្តូរបុគ្គលិកជាន់ខ្ពស់ពាក់ព័ន្ធ។

៤-ការបញ្ឈប់ផ្តល់សេវាទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រដល់អតិថិជនណាមួយ ឬការផ្តល់សេវាទូទាត់សាច់ប្រាក់ជាថ្មី ដល់អតិថិជននោះ។

៥-ការមិនអនុវត្តតាមនីតិវិធីប្រតិបត្តិការទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ របស់អតិថិជន និងចំណាត់ការផ្សេងៗ។

៦-បញ្ហានានាដែលនាំឱ្យការទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ មិនបានសម្រេច។

៧-ការចាត់វិធានការនានា ដើម្បីជំនះលើស្ថានការណ៍លំបាក ឬហានិភ័យផ្សេងៗ ដែលប៉ះពាល់ដល់ការទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ។

៨-ព័ត៌មានផ្សេងទៀត ពាក់ព័ន្ធនឹងប្រតិបត្តិការទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ដែលស្នើសុំដោយអគ្គនាយកនៃ គ.ម.ក.។

**ប្រការ ១៩.- ការផ្តល់ព័ត៌មានក្នុងករណីការទូទាត់សាច់ប្រាក់មិនបានសម្រេច**

ក្នុងករណីអតិថិជនដែលធ្វើប្រតិបត្តិការជួញដូរមូលបត្រ គ្មានលទ្ធភាពធ្វើការទូទាត់ ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ត្រូវជូនដំណឹងទៅឱ្យប្រតិបត្តិករប្រព័ន្ធជាត់ទាត់ និងទូទាត់មូលបត្រ ដោយបញ្ជាក់ឱ្យច្បាស់អំពីអត្តសញ្ញាណរបស់អតិថិជននោះ និងចំនួនទឹកប្រាក់ដែលត្រូវទូទាត់ ឱ្យបានឆាប់ បន្ទាប់ពីការទូទាត់មិនបានសម្រេចកើតមានឡើង។

**ប្រការ ២០.- ការបញ្ឈប់ការផ្តល់សេវាទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រដល់អតិថិជន**

ក្នុងករណីភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រផ្អាកជាបណ្តោះអាសន្ន ឬបញ្ឈប់ការផ្តល់សេវាទូទាត់សាច់ប្រាក់ដល់អតិថិជនណាមួយ ក្រោយពីទទួលបានការអនុញ្ញាតពីអគ្គនាយកនៃ គ.ម.ក. ដូចមានចែងនៅក្នុងប្រការ ១៥ នៃប្រកាសនេះ ភ្នាក់ងារទូទាត់

សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅឱ្យប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ។

**ប្រការ២១.- ការកែប្រែលក្ខន្តិកៈក្រុមហ៊ុនការតែងតាំង ឬផ្លាស់ប្តូរបុគ្គលិកជាន់ខ្ពស់ពាក់ព័ន្ធ**

ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីការកែប្រែលក្ខន្តិកៈក្រុមហ៊ុន ការតែងតាំង ឬការផ្លាស់ប្តូរបុគ្គលិកជាន់ខ្ពស់ពាក់ព័ន្ធយ៉ាងយូរ ០៧ (ប្រាំពីរ) ថ្ងៃ នៃថ្ងៃធ្វើការ ដល់ **គ.ម.ក.** គិតចាប់ពីកាលបរិច្ឆេទនៃការកែប្រែការតែងតាំង ឬការផ្លាស់ប្តូរ។

**ប្រការ ២២.- ការរក្សាការសម្ងាត់**

អភិបាល និងបុគ្គលិកគ្រប់រូបរបស់ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រត្រូវមានកាតព្វកិច្ចរក្សាការសម្ងាត់វិជ្ជាជីវៈដែលខ្លួនទទួលបានក្នុងការបំពេញភារកិច្ច លើកលែងតែក្នុងករណី ៖

១-ច្បាប់អនុញ្ញាត។

២-មានការបង្គាប់ពីតុលាការ។

៣-ស្នើឡើងដោយអគ្គនាយកនៃ **គ.ម.ក.** ក្នុងគោលបំណងអនុវត្តការងារ។

**ប្រការ ២៣.- ទំនាស់ផលប្រយោជន៍**

អភិបាលរបស់ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រទាំងឡាយណា ដែលមានការពាក់ព័ន្ធពីផលប្រយោជន៍តាមគ្រប់រូបភាព ទោះដោយផ្ទាល់ក្តី ឬដោយប្រយោលក្តីក្នុងការធ្វើសេចក្តីសម្រេចណាមួយ ក្នុងប្រតិបត្តិការទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រដែលធ្វើឡើងដោយកិច្ចប្រជុំក្រុមប្រឹក្សាភិបាល អភិបាលនោះត្រូវធ្វើការជូនដំណឹងឱ្យបានទូលំទូលាយ ដល់សមាជិកផ្សេងទៀតរបស់ក្រុមប្រឹក្សាភិបាល តាមរយៈលិខិតជាលាយលក្ខណ៍អក្សរ ក្នុងរយៈពេលមួយសមស្របមុនកិច្ចប្រជុំក្រុមប្រឹក្សាភិបាល។

អភិបាលដែលមានផលប្រយោជន៍ពាក់ព័ន្ធដូចដែលមានចែងក្នុងកថាខណ្ឌទី១ ខាងលើ មិនត្រូវបានអនុញ្ញាតឱ្យចូលរួមក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាល និងមិនអនុញ្ញាតឱ្យចូលរួមបោះឆ្នោតធ្វើសេចក្តីសម្រេចនោះឡើយ។

**ប្រការ ២៤.– ការហាមឃាត់ការទទួលអំណោយ**

អភិបាល និងបុគ្គលិកគ្រប់រូបរបស់ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ សហព័ទ្ធ បុព្វញាតិឬបច្ឆាញាតិរបស់ខ្លួនគិតត្រឹមថ្នាក់ទី៣ មិនត្រូវទទួលអំណោយឬផល-ប្រយោជន៍តាមគ្រប់រូបភាព ពីបុគ្គលដែលខ្លួនមានទំនាក់ទំនងអាជីវកម្ម ឬហិរញ្ញវត្ថុជាមួយ នៅក្នុងការបំពេញមុខងារ និងតួនាទីរបស់ខ្លួន ក្នុងប្រតិបត្តិការទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ។

**ប្រការ ២៥.– ការត្រួតពិនិត្យដោយ គ.ម.ក.**

ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រអាចត្រូវបានត្រួតពិនិត្យ ដែលធ្វើឡើងដោយ **គ.ម.ក.** លើស្ថានភាព និងប្រសិទ្ធភាពនៃប្រតិបត្តិការទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្ររបស់ខ្លួន។

ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ត្រូវផ្តល់កិច្ចសហការល្អដល់មន្ត្រីត្រួតពិនិត្យរបស់ **គ.ម.ក.** ក្នុងគោលដៅធានានូវប្រសិទ្ធភាពការងារ។

## ជំពូកទី ៥
## ទោសប្បញ្ញត្តិ

**ប្រការ ២៦.– វិធានការរដ្ឋបាល**

អគ្គនាយកនៃ **គ.ម.ក.** មានសិទ្ធិដឹកនាំកែតម្រង់ ដាក់លក្ខខណ្ឌ ឬដាក់កំហិតបន្ថែម ព្យួរ ឬដកហូតការទទួលស្គាល់ ក្នុងករណីដែលភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូល-បត្រ ៖

១-ទទួលបានការទទួលស្គាល់ដោយមធ្យោបាយក្លែងបន្លំណាមួយ។

២-ល្មើសនឹងលក្ខខណ្ឌនៃការទទួលស្គាល់។

៣-ល្មើសនឹងកាតព្វកិច្ចដែលមានចែងក្នុងប្រកាសនេះ។

៤-មិនធ្វើតាមការណែនាំរបស់អគ្គនាយកនៃ **គ.ម.ក.** ក្នុងការកែតម្រង់ផ្សេងៗ។

៥-នៅតែបន្តប្រតិបត្តិការទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ក្នុងអំឡុងពេលព្យួរការទទួលស្គាល់។

៦-ផ្អាកជាបណ្តោះអាសន្ន ឬបញ្ឈប់ប្រតិបត្តិការទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ដល់អតិថិជន ដោយមិនទទួលបានការអនុញ្ញាតជាមុនពីអគ្គនាយកនៃ **គ.ម.ក.**។

៧-មិនអាចអនុវត្តសេចក្តីសម្រេចរបស់តុលាការ ដែលតម្រូវឱ្យសងបំណុលមួយភាគ ឬទាំងស្រុងទៅបុគ្គលពាក់ព័ន្ធ។

៨-កំពុងស្ថិតនៅក្នុងស្ថានភាពបច្ចេកទេស និង/ឬហិរញ្ញវត្ថុទន់ខ្សោយ ឬកំពុងត្រូវរំលាយ ដោយគ្មានលទ្ធភាពធ្វើអាជីវកម្មបន្ត ឬដោយការវិនិច្ឆ័យរបស់តុលាការទៅតាមមូលហេតុស្របច្បាប់។

៩-ប្រព្រឹត្តល្មើសនឹងច្បាប់ អនុក្រឹត្យ ប្រកាសនេះ និងបទប្បញ្ញត្តិផ្សេងទៀត។

**ប្រការ ២៧.-ទណ្ឌកម្មការពិន័យអន្តរការណ៍**

ដោយមិនទាន់គិតពីទោសទណ្ឌផ្សេងទៀត ដូចមានចែងក្នុងច្បាប់និងបទប្បញ្ញត្តិក្នុងវិស័យមូលបត្រ និងបទប្បញ្ញត្តិជាធរមាននៃព្រះរាជាណាចក្រកម្ពុជា បុគ្គលទាំងឡាយណាដែលប្រព្រឹត្តល្មើសនឹងប្រកាសនេះ ត្រូវទទួលពិន័យអន្តរការណ៍ពី **គ.ម.ក.** ជាប្រាក់ ពី ៥០.០០០.០០០(ហាសិបលាន)រៀល ដល់ ១០០.០០០.០០០ (មួយរយលាន) រៀល។ ដោយឡែក ចំពោះការយឺតយ៉ាវក្នុងការបង់ថ្លៃការទទួលស្គាល់ ដូចមានចែងក្នុងប្រការ ១០ នៃប្រកាសនេះ ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ត្រូវទទួលការផាកពិន័យអន្តរការណ៍ជាប្រាក់ចំនួន ១.០០០.០០០ (មួយលាន) រៀល ក្នុង ០១ (មួយ) ថ្ងៃ។

## ជំពូកទី ៦
## អវសានប្បញ្ញត្តិ

**ប្រការ ២៨.-គោលការណ៍ណែនាំផ្សេងៗ**

**គ.ម.ក.** អាចចេញគោលការណ៍ណែនាំ ដើម្បីសម្រួលការយល់ដឹង និងការអនុវត្តតាមលក្ខខណ្ឌនៃប្រកាសនេះ ដល់បុគ្គលពាក់ព័ន្ធ អ្នកចូលរួមក្នុងទីផ្សារមូលបត្រ និងដល់សាធារណជន។

**ប្រការ ២៩.-បដិវាទកម្ម**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៣០.– ការអនុវត្ត**

អគ្គនាយក អគ្គនាយករងនៃគណៈកម្មការមូលបត្រកម្ពុជា នាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ នាយកដ្ឋានកិច្ចការគតិយុត្ត នាយកដ្ឋាន អង្គភាពដទៃទៀតចំណុះឱ្យគណៈកម្មការមូលបត្រកម្ពុជា និងបុគ្គលពាក់ព័ន្ធ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែមិថុនា ឆ្នាំ២០១០

**គាត ឈន់**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងយុត្តិធម៌
- ធនាគារជាតិនៃកម្ពុជា
- គណៈកម្មការមូលបត្រកម្ពុជា
- គ្រប់ក្រសួង និងស្ថាប័នពាក់ព័ន្ធ "ដើម្បីជូនជ្រាប"
- ដូចប្រការ ៣០ "ដើម្បីអនុវត្ត"
- អគ្គនាយកដ្ឋានរាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មការមូលបត្រកម្ពុជា

លេខៈ......០០៩/១០....គ.ម.ក/ប្រ.ក

បឋិចិត្តល

ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ2010

# ប្រកាស

## ស្តីពី

## ការទទួលស្គាល់ភ្នាក់ងារបញ្ជិកាមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ និង ភ្នាក់ងារទូទាត់

*****

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មការមូលបត្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០១ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមូលបត្ររដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ/បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ/បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- យោងតាមការអនុម័តនៃសម័យប្រជុំពេញអង្គរបស់គណៈកម្មការមូលបត្រកម្ពុជា នាថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១០

អាសយដ្ឋានបណ្តោះអាសន្ន អគារ ៩៩ ផ្លូវ ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ-កម្ពុជា
Temporary Address: # 99, Street 598, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh, Cambodia. www.secc.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៨៨៥-៦១១ Phone : 855-23-885-611
ទូរសារ : ៨៥៥-២៣-៨៨៥-៦២២ Fax : 855-23-885-622
E-mail : info@secc.gov.kh

# ស ម្រេ ច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-គោលបំណង**

ប្រកាសនេះមានគោលបំណងកំណត់នូវលក្ខខណ្ឌតម្រូវ និងនីតិវិធីដើម្បីទទួលស្គាល់បុគ្គលធ្វើជាភ្នាក់ងារបញ្ជិកាមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ និងភ្នាក់ងារទូទាត់ជំនួស ព្រមទាំងកំណត់អំពីកាតព្វកិច្ចរបស់ភ្នាក់ងារនីមួយៗ ដោយអនុលោមតាមច្បាប់ស្តីពីការបោះ-ផ្សាយ និងការជួញដូរមូលបត្រមហាជន និងអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។

**ប្រការ ២.-និយមន័យ**

និយមន័យនៃពាក្យបច្ចេកទេសដែលប្រើប្រាស់នៅក្នុងប្រកាសនេះ ត្រូវបានកំណត់នៅក្នុងប្រការនេះ និងមាននៅក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។

-ច្បាប់ (Law) សំដៅដល់ច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន។

-អនុក្រឹត្យ (Anukret) សំដៅដល់អនុក្រឹត្យលេខ ៥៤ អនក្រ/បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។

-ភ្នាក់ងារបញ្ជិកាមូលបត្រ (Securities Registrar) សំដៅដល់បុគ្គលដែលទទួលបានការទទួលស្គាល់ពី **គ.ម.ក.** ឱ្យផ្តល់សេវាក្នុងនាមក្រុមហ៊ុនបោះផ្សាយក្នុងក្របខណ្ឌនៃការបោះផ្សាយលក់មូលបត្រ ដូចខាងក្រោម ÷

ក-គ្រប់គ្រងឱ្យបានត្រឹមត្រូវនូវដំណើរការនៃការធ្វើបរិវិសកម្មនិងការបែងចែកមូលបត្រ (Securities Allotment) ស្របតាមនីតិវិធីបោះផ្សាយលក់មូលបត្រ។

ខ-កត់ត្រាបញ្ជីកម្មសិទ្ធិករមូលបត្រក្រោយពេលធ្វើការបែងចែកមូលបត្រត្រូវបានបញ្ចប់នៅទីផ្សារដំបូង ។

គ-ធ្វើរបាយការណ៍ស្តីពីការបញ្ចប់ និងជោគជ័យនៃការរក្សាទុកមូលបត្រនៅប្រតិបត្តិកររក្សាទុកមូលបត្រ ជូនក្រុមហ៊ុនបោះផ្សាយ និង **គ.ម.ក.** ។

ឃ-ជូនដំណឹងដល់កម្មសិទ្ធិករមូលបត្រដោយបញ្ជាក់ពីភាពជាម្ចាស់លើមូលបត្រដែលបានធ្វើបរិវិសកម្មមូលបត្ររបស់ក្រុមហ៊ុនបោះផ្សាយ។

ង-សេវាពាក់ព័ន្ធដទៃទៀតដែលទទួលបានការអនុញ្ញាតពី **គ.ម.ក.**។

-ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ (Securities Transfer Agent) សំដៅដល់បុគ្គលដែលទទួលបានការទទួលស្គាល់ពី **គ.ម.ក.** ឱ្យផ្តល់សេវាក្នុងនាមក្រុមហ៊ុនបោះផ្សាយ ក្រោយពេលមូលបត្រត្រូវបានបែងចែកទៅឱ្យអ្នកធ្វើបរិវិសកម្ម ដូចខាងក្រោម ÷

ក-រក្សា និងគ្រប់គ្រងបញ្ជីកម្មសិទ្ធិករមូលបត្ររួមទាំងព័ត៌មានលំអិតរបស់កម្មសិទ្ធិករមូលបត្រឱ្យមានសង្គតិភាពជាមួយនឹងកំណត់ត្រារបស់ប្រតិបត្តិកររក្សាទុកមូលបត្រ។

ខ-រដ្ឋបាលកិច្ចពាក់ព័ន្ធនឹងការផ្លាស់ប្តូរកម្មសិទ្ធិ ការធ្វើរបាយការណ៍ ស្ថិតិ និងព័ត៌មានផ្សេងៗពាក់ព័ន្ធនឹងសកម្មភាពរបស់ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ។

គ-រៀបចំការងារពាក់ព័ន្ធនឹងសិទ្ធិកម្មសិទ្ធិករមូលបត្រ ដែលត្រូវផ្តល់ដោយក្រុមហ៊ុនបោះផ្សាយ (Corporate actions) ដូចជាការជូនដំណឹងអំពីការបែងចែកភាគលាភ ការបង់ការប្រាក់ ជាដើម។

ឃ-បញ្ជូនរបាយការណ៍ និងព័ត៌មានផ្សេងៗរបស់ក្រុមហ៊ុនបោះផ្សាយទៅដល់កម្មសិទ្ធិករមូលបត្រ និងដោះស្រាយបញ្ហាទាក់ទងនឹងភាពជាម្ចាស់លើមូលបត្រពាក់ព័ន្ធនឹងសេវារបស់ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ។

ង-សេវាពាក់ព័ន្ធដទៃទៀតដែលទទួលបានការអនុញ្ញាតពី **គ.ម.ក.**។

-ភ្នាក់ងារទូទាត់ ឬភ្នាក់ងារទូទាត់ជំនួស (Paying Agent) សំដៅដល់បុគ្គលដែលទទួលបានការទទួលស្គាល់ពី **គ.ម.ក.** ឱ្យផ្តល់សេវាក្នុងនាមក្រុមហ៊ុនបោះផ្សាយ ដូចខាងក្រោម ÷

ក-គណនាភាគលាភ ការប្រាក់ ប្រាក់ដើម ឬការទូទាត់ផ្សេងទៀតដែលត្រូវផ្តល់ឱ្យដល់កម្មសិទ្ធិករមូលបត្រ ឬភាគីពាក់ព័ន្ធ តាមការណែនាំរបស់ក្រុមហ៊ុនបោះផ្សាយ។

ខ-ធ្វើការទូទាត់ជូនកម្មសិទ្ធិករមូលបត្រ ឬភាគីពាក់ព័ន្ធក្នុងនាមក្រុមហ៊ុនបោះផ្សាយ។

គ-បញ្ជូនព័ត៌មានចាំបាច់ដែលពាក់ព័ន្ធនឹងការទូទាត់ ឬព័ត៌មានផ្សេងទៀតដល់កម្មសិទ្ធិករមូលបត្រ និងរៀបចំរបាយការណ៍ពាក់ព័ន្ធនឹងការទូទាត់ទាំងនេះជូនទៅក្រុមហ៊ុនបោះផ្សាយ និង **គ.ម.ក.** តាមការចាំបាច់។

ឃ-សេវាពាក់ព័ន្ធដទៃទៀតដែលទទួលបានការអនុញ្ញាតពី **គ.ម.ក.**។

-បុគ្គលដាក់ពាក្យស្នើសុំ (Applicant) សំដៅដល់បុគ្គលដាក់ពាក្យស្នើសុំធ្វើជាភ្នាក់ងារបញ្ជិកាមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ ឬភ្នាក់ងារទូទាត់។

-បុគ្គលិកជាន់ខ្ពស់ (Senior staff) សំដៅដល់បុគ្គលិកដែលមានឋានៈចាប់ពីអគ្គនាយករហូតដល់នាយកឬប្រធានផ្នែក រួមទាំងលេខាធិការក្រុមហ៊ុន និងសវនករផ្ទៃក្នុង។

-អភិបាល (Director) សំដៅដល់ប្រធានក្រុមប្រឹក្សាភិបាល និងសមាជិកក្រុមប្រឹក្សាភិបាលរបស់បុគ្គលដាក់ពាកស្នើសុំ ឬរបស់ភ្នាក់ងារបញ្ជិកាមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ ឬភ្នាក់ងារទូទាត់។

## ជំពូកទី ២
## លក្ខខណ្ឌនៃការទទួលស្គាល់

### ប្រការ ៣.-ការដាក់ពាក្យស្នើសុំ

បុគ្គលដែលមានបំណងធ្វើជាភ្នាក់ងារបញ្ជិកាមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ ឬភ្នាក់ងារទូទាត់ ត្រូវជាក្រុមហ៊ុនដែលចុះបញ្ជីពាណិជ្ជកម្មស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និងត្រូវដាក់ពាក្យស្នើសុំដើម្បីបានការទទួលស្គាល់ពីអគ្គនាយកនៃ **គ.ម.ក.**។

### ប្រការ ៤.-បុគ្គលដាក់ពាក្យស្នើសុំ

បុគ្គលដាក់ពាក្យស្នើសុំធ្វើជាភ្នាក់ងារបញ្ជិកាមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ ឬភ្នាក់ងារទូទាត់អាចជា÷

១-ប្រតិបត្តិកររក្សាទុកមូលបត្រដែលទទួលបានការអនុញ្ញាតពី **គ.ម.ក.**។

២-ធនាគារពាណិជ្ជដែលទទួលបានអាជ្ញាបណ្ណពីធនាគារជាតិនៃកម្ពុជា។

៣-ក្រុមហ៊ុនមូលធនផ្សេងទៀត ដូចមានចែងក្នុងច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម។

ក្នុងករណីបុគ្គលដាក់ពាក្យស្នើសុំធ្វើជាភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រដែលមិនមែនជាប្រតិបត្តិកររក្សាទុកមូលបត្រ បុគ្គលត្រូវមានកិច្ចសន្យាជាមួយប្រតិបត្តិកររក្សាទុកមូលបត្រស្តីពីការផ្តល់ព័ត៌មាននៃការផ្លាស់ប្តូរកំណត់ត្រាភាពជាម្ចាស់កម្មសិទ្ធិលើមូលបត្រ ដែលគ្រប់គ្រងដោយប្រតិបត្តិកររក្សាទុកមូលបត្រ។

## ប្រការ ៥.- លក្ខខណ្ឌតម្រូវសម្រាប់បុគ្គលដាក់ពាក្យស្នើសុំ

បុគ្គលដាក់ពាក្យស្នើសុំធ្វើជាភ្នាក់ងារបញ្ជិកាមូលបត្រ ឬភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ ឬភ្នាក់ងារទូទាត់ជំនួសត្រូវ ៖

១-មានដើមទុនអប្បបរមាជារូបិយវត្ថុជាតិចំនួន ៖

ក-២០០.០០០.០០០ (ពីររយលាន) រៀល ក្នុងករណីស្នើសុំធ្វើជាភ្នាក់ងារបញ្ជិកាមូលបត្រ។

ខ-២០០.០០០.០០០ (ពីររយលាន) រៀល ក្នុងករណីស្នើសុំធ្វើជាភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ។

គ-៥០០.០០០.០០០ (ប្រាំរយលាន) រៀល ក្នុងករណីស្នើសុំធ្វើជាភ្នាក់ងារទូទាត់។

២-ដាក់ប្រាក់តម្កល់ ១០ (ដប់) ភាគរយនៃដើមទុនអប្បបរមា នៅក្នុងគណនីរបស់ **គ.ម.ក.** នៅធនាគារជាតិនៃកម្ពុជា។ ក្នុងករណីចាំបាច់ ប្រាក់តម្កល់នេះ អាចដកយកមកប្រើប្រាស់បាន ដោយមានការអនុញ្ញាតជាមុនពី **គ.ម.ក.**។

៣-មានវិធានស្តីពីសេវា និងយន្តការក្នុងការផ្តល់សេវាដូចមានចែងក្នុងប្រការ ៩ នៃប្រកាសនេះ។

៤-មានប្រព័ន្ធបច្ចេកវិទ្យាសម្រាប់ធ្វើប្រតិបត្តិការ និងប្រព័ន្ធទ្រទ្រង់ ដើម្បីធានាឱ្យបាននូវប្រតិបត្តិការប្រកបដោយសុវត្ថិភាព ប្រសិទ្ធភាព និងចិរភាព។

៥-មានអង្គភាពឬផ្នែកដាច់ដោយឡែក ដែលមានទ្រព្យនិងធនធានមនុស្សគ្រប់គ្រាន់ និងត្រូវបានគ្រប់គ្រងត្រឹមត្រូវសម្រាប់ផ្តល់សេវាជាភ្នាក់ងារបញ្ជិកាមូលបត្រ ឬភ្នាក់ងារចុះ-បញ្ជីផ្ទេរមូលបត្រ ឬភ្នាក់ងារទូទាត់ ដើម្បីធានាបាននូវប្រសិទ្ធភាព គណនេយ្យភាព តម្លាភាព និងភាពទទួលខុសត្រូវ។ ករណីបុគ្គលដាក់ពាក្យស្នើសុំធ្វើជាភ្នាក់ងារបញ្ជិកាមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ និងភ្នាក់ងារទូទាត់ បុគ្គលនេះអាចមានរចនាសម្ព័ន្ធមួយសម្រាប់បំពេញសេវាភ្នាក់ងារទាំងបីនេះ នៅក្នុងអង្គភាពឬផ្នែកមួយដាច់ដោយឡែក។

៦-មានបុគ្គលដែលត្រូវតែងតាំងជាប្រធានផ្នែកប្រតិបត្តិការក្នុងការផ្តល់សេវាជាភ្នាក់ងារបញ្ជិកាមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ ឬភ្នាក់ងារទូទាត់ ដែលបំពេញលក្ខខណ្ឌតម្រូវដូចមានចែងក្នុងប្រការ ៨ នៃប្រកាសនេះ។

ធនាគារពាណិជ្ជ ឬប្រតិបត្តិកររក្សាទុកមូលបត្រ អាចបង្កើតបុត្រសម្ព័ន្ធដើម្បីដាក់ពាក្យស្នើសុំធ្វើជាភ្នាក់ងារបញ្ជិកាមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ ឬភ្នាក់ងារទូទាត់។ ក្នុងករណីបុគ្គលដាក់ពាក្យស្នើសុំជាធនាគារពាណិជ្ជ ឬប្រតិបត្តិកររក្សាទុកមូលបត្រ លក្ខខណ្ឌតម្រូវស្តីពីដើមទុនអប្បបរមាដូចមានចែងក្នុងកថាខណ្ឌទី ១ ចំនុចទី ១ នៃប្រការនេះត្រូវបានលើកលែង។

ក្នុងករណីបុគ្គលដាក់ពាក្យស្នើសុំជាក្រុមហ៊ុនមូលធនផ្សេងទៀត ដែលកំពុងធ្វើសកម្មភាពធុរកិច្ច បុគ្គលដាក់ពាក្យស្នើសុំត្រូវបន្ថែមដើមទុនដូចមានចែងក្នុងកថាខណ្ឌទី ១ ក្នុងចំណុច ១ នៃប្រការនេះ លើដើមទុនបច្ចុប្បន្ន។

**ប្រការ ៦.– លក្ខណៈសម្បត្តិរបស់បុគ្គលដាក់ពាក្យស្នើសុំ**

បុគ្គលដាក់ពាក្យស្នើសុំ បុគ្គលដែលត្រូវតែងតាំងជាអភិបាលនិងបុគ្គលិកជាន់ខ្ពស់របស់បុគ្គលដាក់ពាក្យស្នើសុំ ត្រូវគោរពតាមលក្ខខណ្ឌតម្រូវដូចខាងក្រោម ៖

១-មានលក្ខណសម្បត្តិនិងអត្តចរិតល្អ ដូចមានចែងក្នុងមាត្រា ៤២ នៃអនុក្រឹត្យ។

២-មិនធ្លាប់ត្រូវបានប្រកាសក្ស័យធន ឬមិនធ្លាប់បង្កឱ្យក្រុមហ៊ុនមួយឬច្រើនឈានទៅរកភាពក្ស័យធនក្នុងរយៈពេល ០៥ (ប្រាំ) ឆ្នាំចុងក្រោយគិតត្រឹមថ្ងៃដាក់ពាក្យស្នើសុំ។

៣-មិនធ្លាប់ប្រព្រឹត្តអំពើអ្វីដែលនាំឱ្យប៉ះពាល់ដល់ដំណើរការទីផ្សារមូលបត្រ ឬនៅក្នុងវិស័យហិរញ្ញវត្ថុ។

៤-មិនធ្លាប់ប្រព្រឹត្តអ្វីដែលប៉ះពាល់ដល់ផលប្រយោជន៍សាធារណៈ។

**ប្រការ ៧.– ឯកសារភ្ជាប់ជាមួយពាក្យស្នើសុំ**

បុគ្គលដាក់ពាក្យស្នើសុំត្រូវបំពេញបែបបទនៃពាក្យស្នើសុំ ទៅតាមទម្រង់ដែលបានកំណត់ដោយ **គ.ម.ក.** ដោយភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម ៖

១-វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម ថតចម្លងមានបញ្ជាក់ត្រឹមត្រូវ។

២-ប័ណ្ណប៉ាតង់ និង/ឬវិញ្ញាបនបត្រចុះបញ្ជីអាករលើតម្លៃបន្ថែម ថតចម្លងមានបញ្ជាក់ត្រឹមត្រូវ។

៣-លក្ខន្តិកៈក្រុមហ៊ុនថតចម្លងមានបញ្ជាក់ត្រឹមត្រូវ។

៤-លិខិតបញ្ជាក់ពីដើមទុនអប្បបរមាដូចមានចែងក្នុងប្រការ ៥ នៃប្រកាសនេះ។

៥-រចនាសម្ព័ន្ធគ្រប់គ្រង មុខងារ និងការទទួលខុសត្រូវរបស់បុគ្គលិកនីមួយៗក្នុងរចនាសម្ព័ន្ធគ្រប់គ្រង។

៦-វិធានស្តីពីសេវា។

៧-ផែនការអាជីវកម្មសម្រាប់រយៈពេលយ៉ាងតិច ០៣ (បី) ឆ្នាំ ដោយគិតចាប់ពីកាលបរិច្ឆេទនៃការដាក់ពាក្យស្នើសុំ។

៨-ផែនការគ្រប់គ្រងហានិភ័យ។

៩-បញ្ជីរាយនាមក្រុមហ៊ុនបោះផ្សាយ ដែលបុគ្គលដាក់ពាក្យស្នើសុំធ្លាប់ផ្តល់ ឬមានបំណងផ្តល់សេវាភ្នាក់ងារបញ្ជិកាមូលបត្រ ឬសេវាកម្មភ្នាក់ងារផ្ទេរមូលបត្រ ឬសេវាភ្នាក់ងារទូទាត់។

**ប្រការ ៨.- គុណវុឌ្ឍិរបស់ប្រធានប្រតិបត្តិការ**

បុគ្គលដែលត្រូវតែងតាំងជាប្រធានប្រតិបត្តិការដូចមានចែងក្នុងប្រការ ៥ នៃប្រកាសនេះ ត្រូវមានចំណេះដឹង និងបទពិសោធន៍ពាក់ព័ន្ធនឹងអាជីវកម្មមូលបត្រ ឬវិស័យហិរញ្ញវត្ថុ យ៉ាងតិច ០៣ (បី) ឆ្នាំ ដើម្បីដឹកនាំប្រតិបត្តិការរបស់ភ្នាក់ងារបញ្ជិកាមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ ឬភ្នាក់ងារទូទាត់។

**ប្រការ ៩.- យន្តការនៃការផ្តល់សេវា**

វិធានស្តីពីសេវា និងយន្តការផ្តល់សេវារបស់ភ្នាក់ងារបញ្ជិកាមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ ឬភ្នាក់ងារទូទាត់ ត្រូវបង្កើតឡើងដោយអនុលោមតាមជំពូកទី៣ នៃប្រកាសនេះ និងត្រូវទទួលបានការអនុញ្ញាតពី **គ.ម.ក.**។

រាល់សេវារបស់ភ្នាក់ងារបញ្ជិកាមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ ឬភ្នាក់ងារ-ទូទាត់ ត្រូវធ្វើឡើងតាមរយៈកិច្ចសន្យាជាមួយក្រុមហ៊ុនបោះផ្សាយដែលជាអតិថិជន។

**ប្រការ ១០.- ឯកសារនិងការបំភ្លឺបន្ថែម**

អគ្គនាយកនៃ **គ.ម.ក.** អាចតម្រូវឱ្យបុគ្គលដាក់ពាក្យស្នើសុំផ្តល់ឯកសារ និងបំភ្លឺនូវចំណុច ឬព័ត៌មានផ្សេងទៀតតាមការចាំបាច់ ដើម្បីធានាថាបុគ្គលដាក់ពាក្យស្នើសុំបំពេញបានគ្រប់លក្ខខណ្ឌដែលមានចែងក្នុងប្រកាសនេះ។

**ប្រការ ១១.- ការបដិសេធពាក្យស្នើសុំ**

អគ្គនាយកនៃ **គ.ម.ក.** អាចបដិសេធលើពាក្យស្នើសុំការទទួលស្គាល់ដោយផ្អែកលើមូលហេតុដូចខាងក្រោម ៖

១-បុគ្គលដាក់ពាក្យស្នើសុំមិនបានបំពេញនូវលក្ខខណ្ឌណាមួយ ដែលមានចែងក្នុងប្រកាសនេះ ឬសេចក្តីណែនាំផ្សេងទៀតដែលធ្វើនៅក្រោមប្រកាសនេះ ឬបទប្បញ្ញត្តិជាធរមានដែលពាក់ព័ន្ធផ្សេងទៀត។

២-ព័ត៌មាន ឬឯកសារដែលបុគ្គលដាក់ពាក្យស្នើសុំបានដាក់ជូន **គ.ម.ក.** មានលក្ខណៈក្លែងបន្លំ ឬដែលនាំឱ្យយល់ខុស។

៣-បុគ្គលដាក់ពាក្យស្នើសុំស្ថិតក្នុងស្ថានភាពឈានទៅរកការបញ្ឈប់ ឬរំលាយអាជីវ-កម្ម។

៤-សេចក្តីសម្រេចរបស់តុលាការ ដែលតម្រូវឱ្យបុគ្គលដាក់ពាក្យស្នើសុំ ទូទាត់សងបំណុល មិនត្រូវបានអនុវត្តទាំងស្រុង ឬមួយផ្នែកដោយបុគ្គលដាក់ពាក្យស្នើសុំនោះ។

៥-បុគ្គលដាក់ពាក្យស្នើសុំ ឬអភិបាល ឬបុគ្គលិកជាន់ខ្ពស់របស់បុគ្គលដាក់ពាក្យស្នើសុំ ÷

ក-បានធ្វើអាជីវកម្មដែលមានលក្ខណៈបោកបញ្ឆោត ឬកេងប្រវ័ញ្ច ឬមិនត្រឹមត្រូវដោយប្រការណាមួយ។

ខ-បានប្រព្រឹត្តល្មើសនឹងច្បាប់ ឬបទប្បញ្ញត្តិ ដែលការពារសាធារណជនឱ្យចៀសផុតពីការខាតបង់ផ្នែកហិរញ្ញវត្ថុ ដោយសារតែភាពមិនស្មោះត្រង់ អសមត្ថភាព ឬការប្រព្រឹត្តមិនត្រឹមត្រូវរបស់បុគ្គលនោះ ក្នុងការផ្តល់សេវាហិរញ្ញវត្ថុ ឬក្នុងការគ្រប់គ្រងក្រុមហ៊ុន។

គ-បានធ្វើ ឬជាប់ពាក់ព័ន្ធនឹងអាជីវកម្មណាមួយផ្សេងទៀត ដែលធ្វើឱ្យមានការសង្ស័យចំពោះសមត្ថភាព និងសុក្រឹតភាពនៃសេចក្តីសម្រេចរបស់ខ្លួន។

ឃ-ស្តែងចេញនូវភាពមិនអាចធ្វើសកម្មភាព ដើម្បីផលប្រយោជន៍អតិថិជនរបស់ខ្លួន ដោយសារតែកេរ្តិ៍ឈ្មោះ បុគ្គលិកលក្ខណៈ សេចក្តីសុចរិត និងភាពដែលអាចទុកចិត្តបានផ្នែកហិរញ្ញវត្ថុរបស់បុគ្គលទាំងនោះ។

ង-ស្តែងចេញនូវភាពមិនអាចធ្វើអាជីវកម្មបាន ក្រោមលក្ខខណ្ឌនៃការទទួលស្គាល់ប្រកបដោយប្រសិទ្ធភាព ភាពស្មោះត្រង់ និងយុត្តិធម៌។

៦-នៅពេលកើតមានហេតុការណ៍ណាមួយដែលអាច ÷

ក-នាំឱ្យបុគ្គលដាក់ពាក្យស្នើសុំ ឬអភិបាល ឬបុគ្គលិកជាន់ខ្ពស់ ឬភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់របស់បុគ្គលដាក់ពាក្យស្នើសុំមិនអាចធ្វើអាជីវកម្មបានត្រឹមត្រូវ។

៦-ឆ្លុះបញ្ចាំងពីភាពមិនអាចជឿជាក់បានលើវិធីធ្វើអាជីវកម្ម របស់បុគ្គលដាក់ពាក្យស្នើសុំ។

៧-បុគ្គលដាក់ពាក្យស្នើសុំមាន ឬអាចនឹងមានការពាក់ព័ន្ធនឹងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ឬការទទួលស្គាល់បុគ្គលដាក់ពាក្យស្នើសុំអាចនឹងនាំឱ្យប៉ះពាល់ផលប្រយោជន៍សាធារណៈ។

អគ្គនាយកនៃ **គ.ម.ក.** មិនត្រូវបដិសេធការទទួលស្គាល់លើពាក្យស្នើសុំ ដោយមិនបានផ្តល់មូលហេតុជាលាយលក្ខណ៍អក្សរជាមុនឡើយ។

## ជំពូកទី ៣
## វិធានស្តីពីសេវា និងផែនការអាជីវកម្ម របស់ភ្នាក់ងារបញ្ជិកាមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ និងភ្នាក់ងារទូទាត់

### ប្រការ ១២.- វិធានស្តីពីសេវារបស់ភ្នាក់ងារបញ្ជិកាមូលបត្រ

វិធានស្តីពីសេវាភ្នាក់ងារបញ្ជិកាមូលបត្រ របស់បុគ្គលដាក់ពាក្យស្នើសុំធ្វើជាភ្នាក់ងារបញ្ជិកាមូលបត្រដូចមានចែងក្នុងប្រការ ៥ នៃប្រកាសនេះ ត្រូវចែងពីនីតិវិធីទាក់ទងនឹងប្រតិបត្តិការសេវាកម្មរបស់ភ្នាក់ងារបញ្ជិកាមូលបត្រ។ វិធានស្តីពីសេវារបស់ភ្នាក់ងារបញ្ជិកាមូលបត្រត្រូវមានចែងជាអប្បបរមានូវ ៖

១-វិសាលភាពនៃសកម្មភាពសេវា និងប្រភេទមូលបត្របោះផ្សាយដែលពាក់ព័ន្ធ។

២-លក្ខខណ្ឌ និងនីតិវិធីនៃការផ្តល់ ព្យួរ និងបញ្ឈប់សេវា ចំពោះក្រុមហ៊ុនបោះផ្សាយ និងភាគីពាក់ព័ន្ធដទៃទៀត។

៣-កម្រៃសេវានានាដែលកំណត់សម្រាប់ក្រុមហ៊ុនបោះផ្សាយ និងភាគីពាក់ព័ន្ធ។

៤-សិទ្ធិ និងកាតព្វកិច្ចរបស់ក្រុមហ៊ុនបោះផ្សាយដែលជាអតិថិជន និងភាគីពាក់ព័ន្ធដទៃទៀតក្នុងការទទួលយកសេវាបញ្ជិកាមូលបត្រ។

៥-និទ្ទេសដែលតម្រូវឱ្យចែងនៅក្នុងកិច្ចព្រមព្រៀងសេវាបញ្ជិកាមូលបត្រ ដែលនឹងធ្វើជាមួយក្រុមហ៊ុនបោះផ្សាយមូលបត្រដែលជាអតិថិជន និងភាគីពាក់ព័ន្ធដទៃទៀត។

៦-វិធីសាស្ត្រស្តីពីការអនុវត្តនូវការបែងចែកមូលបត្រ ការកត់ត្រាបញ្ជិកានៃភាពជាម្ចាស់កម្មសិទ្ធិលើមូលបត្រក្រោយការធ្វើឯកជនភាវូបនីយកម្ម។

